# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥៧

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានបន្តស្តាប់សក្ខីកម្មរបស់លោក **កាំង ហ្គេចអ៊ាវ** ដែលត្រូវបានស្គាល់ជាទូទៅដោយឈ្មោះបដិវត្តន៍របស់គាត់ដែលមានរហស្សនាមថា “**ឌុច**” ហើយគាត់បានផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីលើអង្គហេតុមន្ទីរសន្តិសុខ ស-២១ នៅក្នុងសំណុំរឿង០០២ វគ្គ២។[1] សាក្សី ឌុច បានចាប់ផ្តើមផ្តល់សក្ខីកម្មរបស់គាត់កាលពីសប្តាហ៍មុន ហើយនឹងបន្តរហូតដល់ចុងសប្តាហ៍ក្រោយផងដែរ។ សាក្សីរូបនេះ ត្រូវបានចោទសួរដេញដោលដោយការិយាល័យសហព្រះរាជអាជ្ញា មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងចៅក្រមលើប្រធានបទជាច្រើន រួមមាន៖ ការបោសសម្អាតផ្ទៃក្នុង ការប្រព្រឹត្តលើជនជាតិភាគតិចចាម ជនជាតិភាគតិចវៀតណាម និងអតីតទាហាន **លន់ នល់** ក៏ដូចជាការសួរចម្លើយអ្នកទោស និងការធ្វើទារុណកម្មជាដើម។ ក្នុងវគ្គ

---

[1] លោក **កាំង ហ្គេចអ៊ាវ** បានផ្តើមផ្តល់សក្ខីកម្មរបស់គាត់កាលពីថ្ងៃអង្គារ ទី៧ ខែមិថុនា ឆ្នាំ២០១៦។ សម្រាប់សេចក្តីសង្ខេបអំពីសក្ខីកម្មរបស់គាត់នៅពេលនោះ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ វគ្គ២ លេខ៥៦ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥៣ (ចុះថ្ងៃទី៦-៩ ខែមិថុនា ឆ្នាំ២០១៦)។ គាត់ក៏ធ្លាប់បានមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីផងដែរ ក្នុងសំណុំរឿង០០២ វគ្គ១ ដោយបានប្រើប្រាស់រយៈពេលចំនួន ១២ថ្ងៃ នៅចន្លោះថ្ងៃទី១៩ ខែមីនា ដល់ទី១០ ខែមេសា ឆ្នាំ២០១២។ សម្រាប់សេចក្តីសង្ខេប ស្តីពីសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង០០២ វគ្គ១ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ លេខ១៥ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១០ (ចុះថ្ងៃទី១៩-២១ ខែមីនា ឆ្នាំ២០១២), របាយការណ៍លេខ១៦ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១១ (ចុះថ្ងៃទី២៦-២៩ ខែមីនា ឆ្នាំ២០១២), របាយការណ៍លេខ១៧ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១២ (ចុះថ្ងៃទី២-៥ ខែមេសា ឆ្នាំ២០១២), របាយការណ៍លេខ១៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១៣ (ចុះថ្ងៃទី៩-១០ ខែមេសា ឆ្នាំ២០១២)។

បញ្ចប់នៅថ្ងៃព្រហស្បតិ៍ មេធាវីការពារក្ដីឲ្យជនជាប់ចោទលោក **នួន ជា** បានចាប់ផ្ដើមតាំងសំណួរដេញដោលទៅកាន់សាក្សី **ឌុច** តែឥរិយាបថរបស់គាត់បានផ្លាស់ប្ដូរគួរឲ្យកត់សម្គាល់ ដោយប្រែក្លាយជាមិនសូវសហការទៅវិញនៅពេលដែលមេធាវីការពារក្ដីសួរសំណួរដេញដោល។ រីឯបញ្ហាពាក់ព័ន្ធនឹងភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម បានរំខានដល់កិច្ចដំណើរការនីតិវិធីសវនាការសាជាថ្មីម្ដងទៀតក្នុងសប្ដាហ៍នេះ។ ទោះបីជាយ៉ាងណានេះក្ដី បញ្ហាលើកនេះ គឺកើតចេញពីចៅក្រម និងការិយាល័យសហព្រះរាជអាជ្ញា មិនមែនក្រុមមេធាវីការពារក្ដីនោះទេ ហើយពួកគេត្រូវបានរារាំងក្នុងការប្រើប្រាស់ឯកសារទាំងនោះ។ នៅវគ្គបញ្ចប់នាសប្ដាហ៍នេះ សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើបទបង្ហាញអំពីសំណើលើគម្រោងសំណងនានាដែលស្នើឲ្យអនុវត្ត នៅពេលណាដែលជនជាប់ចោទណាមួយ ត្រូវបានរកឃើញថាមានពិរុទ្ធភាព ចំពោះបទចោទប្រកាន់ណាមួយប្រឆាំងនឹងពួកគេក្នុងសំណុំរឿង០០២ វគ្គ២។ សាក្សី **ឌុច** នឹងបន្តផ្ដល់សក្ខីកម្មរយៈពេលបួនថ្ងៃពេញនៃសវនាការបន្តទៀតនៅសប្ដាហ៍ក្រោយ ហើយនឹងត្រូវបានសួរដេញដោលដោយក្រុមមេធាវីការពារក្ដីទាំងពីរ។ បន្ថែមលើសក្ខីកម្មរបស់ **ឌុច** ដែលត្រូវបានស្ដាប់ពេញមួយសប្ដាហ៍នេះ របាយការណ៍នេះ ក៏បានរៀបរាប់លម្អិតផងដែរស្ដីពីសក្ខីកម្មរបស់សាក្សីចំនួនពីររូប គឺអ្នកស្រី **យូ វ៉ាន់** និងអ្នកស្រី **ប្រាក់ យុត** ដែលបានផ្ដល់សក្ខីកម្មកាលពីខែ មករា ឆ្នាំ ២០១៦ កន្លងទៅ។ កម្មាភិបាលស្រីពីររូបមកពីភូមិភាគនិរតី បានផ្ដល់សក្ខីកម្មក្នុងវគ្គសវនាការអសាធារណៈក្នុងអំឡុងពេលនៃផ្នែកជំនុំជម្រះស្ដីពីការប្រព្រឹត្តលើជាជាតិភាគតិចចាម។ តុលាការ បានធ្វើការផ្សព្វផ្សាយនូវប្រតិចារឹកដែលមានកោសលប់ ស្ដីពីសក្ខីកម្មរបស់សាក្សីទាំងពីរនេះផងដែរក្នុងសប្ដាហ៍នេះ ដូច្នេះហើយបានជារបាយការណ៍ប្រចាំសប្ដាហ៍នេះបានដាក់បញ្ចូលសេចក្ដីសង្ខេបនៃសក្ខីកម្មរបស់អ្នកទាំងពីរនេះ។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ លេណា ហារីស-ផមមើរ៉យ (Lena Harris-Pomeroy), គុំ សុម៉ាលី, ខេតលីន កាហ្វ្រៀ (Caitlin McCaffrie), នំ វិសុទ្ធ, តាយ លីណា និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើនដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University